# Khmer A: literature – Standard level – Paper 1
# Khmer A : littérature – Niveau moyen – Épreuve 1
# Khmer A: literatura – Nivel medio – Prueba 1

Wednesday 10 May 2017 (afternoon)
Mercredi 10 mai 2017 (après-midi)
Miércoles 10 de mayo de 2017 (tarde)

1 hour 30 minutes / 1 heure 30 minutes / 1 hora 30 minutos

---

### Instructions to candidates

- Do not open this examination paper until instructed to do so.
- Write a guided literary analysis on one passage only. In your answer you must address both of the guiding questions provided.
- The maximum mark for this examination paper is **[20 marks]**.

### Instructions destinées aux candidats

- N'ouvrez pas cette épreuve avant d'y être autorisé(e).
- Rédigez une analyse littéraire dirigée d'un seul des passages. Les deux questions d'orientation fournies doivent être traitées dans votre réponse.
- Le nombre maximum de points pour cette épreuve d'examen est de **[20 points]**.

### Instrucciones para los alumnos

- No abra esta prueba hasta que se lo autoricen.
- Escriba un análisis literario guiado sobre un solo pasaje. Debe abordar las dos preguntas de orientación en su respuesta.
- La puntuación máxima para esta prueba de examen es **[20 puntos]**.

2217 – 0567



© International Baccalaureate Organization 2017

សូមអ្នកធ្វើការវិភាគបែបអក្សរសិល្ប៍ទៅលើអត្ថបទ**មួយ**គត់។ ក្នុងចម្លើយរបស់អ្នក អ្នកត្រូវឆ្លើយតបនឹងសំណួរទាំងពីរដែលបានចោទសួរ។

**1.**

ចាប់តាំងពីថ្ងៃនោះមក នារីនាងក៏ទៅជានៅក្រោមអំណាចស៊ីណាតគ្រប់គ្រង មិនឱ្យដើរទៅណាបាន ប្រៀបដូចជាសត្វជាប់ក្នុងទ្រុងគេ ។

ចំណែកខាងស៊ីណាត រង់ចាំឱ្យតែបានដំណឹងថា បិតានាងនៅឯណា គិតឱ្យមាតាបិតាខ្លួនចូលទៅស្តីដណ្តឹង ។ នារីកាលបើបានដឹងទឹកចិត្តស៊ីណាតដូច្នោះហើយ នាងចេះតែមានសេចក្តីនឹកព្រួយបារម្ភគ្រប់ពេលវេលា មុខមិនដែលរីក បាយពុំសូវបាន ពេលយប់និទ្រាពុំហ៊ានឱ្យលក់ស្កប់ស្កល់ ។ ក្នុងចិត្តតែងតែនឹកព្រួយខ្លាចស៊ីណាត ក្រែងហ៊ានរំលោភបំពានប៉ះពាល់ដល់រូបកាយដោយការពុំគប្បី រាត្រីមួយនាងនឹកថា ឱលោកអ្នកមានគុណរបស់កូនអើយ ! ម្តេចឡើយលោកយកកូនមកបោះបង់ចោលមិននឹកនា ហាក់ដូចជាយកកូនមកផាត់បំណុលឱ្យគេយ៉ាងដូច្នេះ ឬមួយលោកគិតប្រាថ្នាឱ្យកូនទៅរួបស៊ីណាតទេដឹងអើយ បានជាលោកធ្វើព្រងើយកន្តើយ គ្មាននឹកនាមកកូនបន្តិចបន្តួចសោះឡើយ ។ “ឱរូបអញអើយ ! កម្មអ្វីក្រាសម្លេះឱ្យចេះតែទទួលទុក្ខច្រើនលើកច្រើនគ្រាពុំចេះបានស្បើយសោះ តើតទៅអនាគតអញនឹងមានបុណ្យព្រេងវាស្នាដែរឬទេ?” ។

ពេលនោះយប់យន់កាន់តែជ្រៅណាស់ទៅហើយ យូរ ៗសម្លេងម្ញញរបស់ឆ្កែ ឮមកដល់ត្រចៀកនាងម្តងៗ សម្លេងលលក ខ្មោច ចង្រិតដែកស្រែកបន្តគ្នាយ៉ាងស្រួយគ្មានចេះឈប់ឈរ បំណែកក្លិនបុប្ផាសនានា មានរដូលចន្ទ ម្លិះរួត ម្លិះលា ចម្ប៉ាក្តាំងងា ដែលផ្ញើជីវិតរស់នៅជុំវិញផ្ទះថ្មីនេះ ក៏ដណ្តើមគ្នាបង្ហើរក្លិនលេងតាមវាយោ ជំនោវាយោក៏ដឹកនាំក្លិនបុប្ផាបញ្ចូលតាមចន្លោះបង្អួចតូចមួយ នៅក្នុងបន្ទប់ដំណេករបស់នាង ។

ណាត្រី កាលបើបានស្រូបពិដោឈ្ងុយឈ្ងុបទាំងនេះ ទឹកភ្នែកក៏ហូរស្រក់ច្រោកៗ ជោកខ្នើយដែលនាងកើយ ។ នារីក្រោកចាកអំពីដំណេកម្នីម្នាអង្គុយលើកៅអី នៅមុខតុតូចមួយដែលមានសៀវភៅពីរបី ទឹកខ្មៅនឹងដងប៉ាកា ព្រមទាំងពន្លឺចង្កៀងប្រេងកាតប្លុងៗ នៅលើនោះ ទើបនាងនឹកថា : “សេចក្តីទុក្ខរបស់អញអើយ ! សមជាបែកទ្រូងស្លាប់ទេដឹង ? ដោយគ្មានញាតិរបស់អញឯណាម្នាក់ដែលល្មមគួរទុកចិត្ត ដើម្បីពោលទុក្ខទាំងនេះប្រាប់គ្រាន់បានធូរទ្រូងផង បើដូច្នេះមានតែអញកត់ចារសេចក្តីទុកនៅលើក្រដាសក្រែងបានស្បើយ សោះចុកណែនឱរាពេក” ទើបនាងចាប់ដងប៉ាកាបង្ហូរទឹកខ្មៅទៅលើ ក្រដាសមួយសន្លឹក មានសេចក្តីថា :

*ឱ ! ផ្ការំដួលអើយ ! ខ្ញុំពុំភ្លេចអ្នកទេ កាលដែលខ្ញុំបានជួបនឹងអ្នកនៅទីវាលនៃពពួកអ្នកគង្វាលគោនោះ ។*

*ចន្ទអើយ ! ក្លិនអ្នកម្តេចខ្សោយជាងគេម្ល៉េះ ? តើអ្នកនៅនាស្ថានឯណា ? តែចិត្តរបស់ខ្ញុំនឹកអ្នកគ្មានឈប់ឈរទេ ពេលដែលអ្នកថិតនាលើអាកាស រស្មីបំភ្លឺចាំងមកលើដើមស្វាយ នៅក្នុងចំការពោតនូវកណ្តាលរាត្រីស្ងាត់នោះ......*

*ចំណែកបុប្ផានានា ចម្ប៉ាក្តាំងងា ក្នុងគ្រានេះពិតមែនតែខ្លួនខ្ញុំនៅឆ្ងាយអំពីអ្នក តែចិត្តខ្ញុំសុំប្តេជ្ញាថា : ក្លិនក្រអូបវិសេសរបស់អ្នកយ៉ាងណា សេចក្តីស្នេហារបស់ខ្ញុំក៏មានខ្លឹមសារខ្លាំងក្លាស្មើនឹងអ្នកដែរ ។*

*បើទុកណាជាអ្នកណាមួយ ទៅបេះប្រឡេះឱ្យអស់រលីងចេញពីដើម មិនយូរប៉ុន្មានគង់អ្នកពន្លករីកស្គុះស្គាយឡើងមកទៀត មិនចេះអស់ទេ ក្រែងតែអ្នកដាច់ដួងកែវជីវិត ទើបបានផុតរូបនិងចិត្តរបស់ខ្ញុំក៏ដូចជាអ្នកដែរ ។*

*ហត្ថលេខា*
*ណាត្រី*

កាលបើនាងប្រព្រឹត្តសេចក្តីទុក្ខសង្រេងសង្រៃយ៉ាងដូច្នេះ យូរថ្ងៃទៅខ្លួននាងក៏ស្គមនៅស្បែកនិងឆ្អឹង សាច់ឡើងស្លេកស្លាំង មុខឡើងជ្រុង មើលទៅឃើញអាក្រក់ខុសប្លែកឆ្ងាយជាងពីដើម ។

ស៊ីណាតឃើញនាងមានរូបរាងអាក្រក់ដូច្នោះ យុវជននេះក៏បែកចិត្តរើគំនិតផ្លាស់ជាថ្មីឡើងថា : “នារីនេះមានរូបរាងអាក្រក់ណាស់ទេតើ សម្បត្តិទ្រព្យសោតក៏គ្មាន សាត់តគ្រាត់មកតែខ្លួនទទេប្រវេប្រវាមកនៅដោយសារនឹងផ្ទះអញ គិតមើលទៅមិនសមរម្យនឹងរូបព្រមទាំងធនធានរបស់អញឡើយ បើដូច្នោះតាំងពីថ្ងៃនេះទៅអញមិនត្រូវវីវរចងចិត្តមេត្រីចំពោះស្រីនេះទៀតទេ ចាំដល់ថ្ងៃណាសូមឱ្យឪពុកម្តាយអញទៅនិយាយស្តីដណ្តឹងកូនក្រមុំគេដែលជាអ្នកមានស្តុកស្តម្ភនៅជិតផ្សារឯណោះវិញ ទើបបានសមសួនថ្កុំថ្កើនល្មមសមភាពរបស់អញ ..................
........................................................................................................................................................

ស៊ុយ ហៀង, *វាសនានាងណាគ្រី* (1999)

(a) ចូរធ្វើការវិភាគតួអង្គណាគ្រី និង ស៊ីណាត នៅក្នុងអត្ថបទដកស្រង់នេះ។

(b) ចូរធ្វើបកស្រាយទៅលើការប្រើបច្ចេកទេសផ្នែកអក្សរសាស្ត្រផ្សេងៗ ដើម្បីបង្ហាញគំនិតសំខាន់របស់អត្ថបទដកស្រង់នេះ។

**2.**

## ស្រវឹងនឹងពាក្យសរសើរ ចិត្តមិនស្ងប់

ស្រវឹងនឹងពាក្យសរសើរ    ជាដំណើរថយស្មារតី
ស្រវឹងក្លាសំដី    មិនប្រក្រតី ផ្នែកគំនិត    ។
ឫកពាមិនថ្លៃថ្នូរ    ពាក្យមូទូ ច្រើនភ្លេចគិត
ស្រវឹងរីករវចិត្ត    ច្រើនព្រឹត្ត ផ្ទុយនឹងច្បាប់    ។
អ្នកស្រវឹងតែងចង់    តាមភាពល្ងង់ នូវពាក្យគាប់
ពាក្យគួរសរសើរជាប់    ជាទម្លាប់ អ្នកស្រវឹង    ។
បើមានគេរិះគន់    ស្រាលឬធ្ងន់នៅមិននឹង
មានចិត្តប្រកាន់ខឹង    ទោសៈរឹងវែងជាទុក្ខ    ។
នៅពេលដែលស្រវឹង    ត្រចៀលហ៊ឹងក្រហាមមុខ
សរសើរពេញបន្ទុក    មិនដឹងមុខប្លមឬពិត    ។
ពិសេសពួកថ្នាក់ខ្ពស់    លើកកម្ពស់ដោយអ្នកជិត
វាយអែបស៊ីអុកត្បិត    ដឹងទឹកចិត្ត គិតបោកស៊ី    ។
រកសរសើរពិតគ្មាន    ដែលថាមានប្លមពេញទី
សរសើរតាមនាទី    អ្នកជោរស៊ីអត់បញ្ញា    ។
ជួនកាលធ្វើត្រូវតិច    គេប្រើល្បិចប៉ងប្រាថ្នា
ចោមរោមសរសើរថា    មនុស្សអស្ចារ្យ រកពីរគ្មាន    ។
មនុស្សដែលស្រវឹង    មិនរំពឹងទៅលើញាណ
ភ្លេចគិតញាតិព្រៀងលាន    គិតតែឃ្លានពាក្យសរសើរ    ។
ស្រវឹងមានច្រើនផ្នែក    បើគេចែក ដោយអន្លើរ
ស្រវឹងនឹងអំពើ    ជាកុសល អកុសល    ។
ស្រវឹងនឹងសម្រស់    ស្អាតឥតខ្ចោះ នរណាដល់?
មានលក្ខណៈសាកល    ទទួលស្គាល់ ពិភពលោក    ។
ស្រវឹងនឹងសក្តិយស    ល្បីទាំងឈ្មោះ មានជ័យជោគ
ស្រវឹងទ្រព្យក្នុងលោក    ឡាន វីឡា ដុល្លារ មាស    ។
អ្វីៗដែលស្រវឹង    មិននៅនឹងតែងវិនាស
ប្តូរផ្លាស់ព្រាត់និរាស    ស្លាប់ងងាស ដៃទទេ    ។

ទេព សាបាន, *កម្រងកំណាព្យ អប់រំ និង រិះគន់* (2004)

(a) ចូរធ្វើការពិភាក្សាទៅលើវិធីសាស្រ្តដែលកវីបានប្រើ ដើម្បីបង្ហាញពីគំនិតចំបងរបស់កំណាព្យនេះ។ តើគំនិតចំបងនេះមានឥទ្ធិពលអ្វីខ្លះដល់អ្នកអាន? ចូរធ្វើការពិភាក្សា។

(b) ចូរធ្វើការបកស្រាយទៅលើការប្រើភាសា និងបច្ចេកទេសផ្នែកអក្សរសាស្រ្តនៅក្នុងកំណាព្យនេះ។ តើការប្រើភាសានិងបច្ចេកទេសផ្នែកអក្សរសាស្រ្តនេះមានឥទ្ធិពលអ្វីខ្លះដល់អ្នកអាន? ចូរធ្វើការបកស្រាយ។